*រាជធានីភ្នំពេញ , ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ១៩៩៥*

# អនុក្រឹត្យលេខ ៣៧ អនក្រ
# ស្តីពីការបង្កើតគណៈកម្មការ
# នៃការថែទាំសុខភាពបឋម

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងសុខាភិបាល

## សំរេច

**មាត្រា ១ :** បង្កើតគណៈកម្មការអន្តរក្រសួងមួយ ដែលមានឈ្មោះថា " គណៈកម្មការអន្តរក្រសួងនៃការ ថែទាំសុខភាពបឋម " ដើម្បីគ្រប់គ្រង និងអនុវត្តកម្មវិធីថែទាំសុខភាពបឋម អោយមានប្រសិទ្ធភាព ។

**មាត្រា ២ :** គណៈកម្មការនៃការថែទាំសុខភាពបឋមមានសមាសភាពដូចខាងក្រោម ÷

| | |
|---|---|
| ១_ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសុខាភិបាល | ប្រធាន |
| ២_ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ | អនុប្រធាន |
| ៣_ឯកឧត្តមរដ្ឋលេខាធិការក្រសួងអប់រំយុវជននិងកីឡា | សមាជិក |
| ៤_ឯកឧត្តមរដ្ឋលេខាធិការ ក្រសួងកសិកម្ម | សមាជិក |
| ៥_ឯកឧត្តមរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | សមាជិក |
| ៦_ឯកឧត្តមរដ្ឋលេខាធិការ ក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន | សមាជិក |
| ៧_ឯកឧត្តមអនុរដ្ឋលេខាធិការ ក្រសួងហិរញ្ញវត្ថុ និងសេដ្ឋកិច្ច | សមាជិក |
| ៨_លោកជំទាវអនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានកិច្ចការនារី | សមាជិក |
| ៩_លោកតំណាងកាកបាទក្រហមកម្ពុជា | សមាជិក |

១០_លោកអភិបាលរងខេត្ត_ក្រុង និង រាជធានីភ្នំពេញ សមាជិក

**មាត្រា ៣ :** គណៈកម្មការអន្តរក្រសួងនៃការថែទាំសុខភាពបឋម ត្រូវមានលេខាធិការដ្ឋានមួយ ជាជំនួយការ ដែលមានសមាសភាពដូចខាងក្រោមនេះ ÷

- ឯកឧត្តមអនុរដ្ឋលេខាធិការ ក្រសួងសុខាភិបាល ប្រធាន
- ឯកឧត្តមអនុរដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ អនុប្រធាន
- លោកប្រធាននាយកដ្ឋានថែទាំសុខភាពបឋម ក្រសួងសុខាភិបាល សមាជិកអចិន្ត្រៃយ៍
- លោកតំណាងក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក
- មន្ត្រីរាជការសុខាភិបាល ៤ រូប សមាជិក

**មាត្រា ៤ :** គណៈកម្មការអន្តរក្រសួង នៃការថែទាំសុខភាពបឋម មានទីតាំងអចិន្ត្រៃយ៍របស់ខ្លួននៅក្នុងទីស្តីការ រដ្ឋមន្ត្រីក្រសួង សុខាភិបាល ហើយមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសុខាភិបាល ។

**មាត្រា ៥ :** គណៈកម្មការអន្តរក្រសួងនៃការថែទាំសុខភាពបឋម មានភារកិច្ចដូចតទៅ ÷

១_ធានាការយល់ដឹងអំពីខ្លឹមសារបច្ចេកទេស និងគោលនយោបាយថែទាំសុខភាពបឋម ដោយមាន ការតំរង់ទិសពីក្រសួងសុខាភិបាល មុនពេលចាប់អនុវត្តនូវគំរោងការ និងកម្មវិធីថែទាំសុខភាព បឋម ។

២_ប្រមូល និងចងក្រងពត៌មាន អំពីកម្មវិធី និងគំរោងការទាំងអស់ក្នុងការផ្តល់ការថែទាំសុខភាព បឋម ដែលកំពុងអនុវត្តនៅកម្ពុជា ។

៣_លើកទឹកចិត្តអោយមានសហប្រតិបត្តិការទៅវិញទៅមក ក្នុងការថែទាំសុខភាពបឋមនៅមូលដ្ឋាន និងជៀសវាង កិច្ចខិតខំប្រឹងប្រែងជាន់គ្នា ។

៤_ត្រួតពិនិត្យគុណភាព សកម្មភាពនៃការថែទាំសុខភាពបឋម ដែលផ្តល់ជូនជនកម្ពុជាគ្រប់រូប រាប់ទាំងស្ត្រី កុមារ និងបុរស ។

៥_លើកសំណើជូនរាជរដ្ឋាភិបាលនូវមធ្យោបាយ :

- ជួយប្រជារាស្ត្រអោយមានលទ្ធភាពទទួលនូវកម្មវិធីថែទាំសុខភាពបឋម
- ចលនាប្រភពធនធានតាមរយៈសប្បុរសជន និងអង្គការអន្តរជាតិនានា សំរាប់សេវាថែ ទាំសុខភាពបឋម ។

លេខាធិការដ្ឋាន មានភារកិច្ចដូចតទៅ :

១_អញ្ជើញគណៈកម្មការចូលរួមប្រជុំ និងតំកល់ទុកឯកសារ និងរបាយការណ៍ផ្សេងៗ

២_តាមដានការអនុវត្តសេចក្តីសំរេច និងមតិណែនាំផ្សេងៗ របស់គណៈកម្មការអន្តរក្រសួង ។ ធ្វើរបាយការណ៍ជូន ទៅរាជរដ្ឋាភិបាល អំពីការអនុវត្តការងារថែទាំសុខភាពបឋមនៅទូទាំងប្រទេស ។

៣_ផ្តល់ការណែនាំបច្ចេកទេស ដើម្បីអោយគ្រប់ស្ថាប័ន និងអង្គការនានាមានការយល់ដឹងអំពីគោលនយោបាយ និងយុទ្ធសាស្ត្រសុខាភិបាល ព្រមទាំងគោលការណ៍ និងខ្លឹមសារនៃការងារថែទាំសុខភាពបឋម ។

៤_សហប្រតិបត្តិការជិតស្និទ្ធជាមួយអង្គការសុខភាពពិភពលោក យូនីសែហ្វ , យូអិនឌីភី , បេឌីគាម , អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលនានា ដើម្បីជួយឧបត្ថម្ភថវិកា និងបច្ចេកទេសដល់ការងារថែទាំសុខភាពបឋម ។

**មាត្រា ៦ :** ស្ថាប័ន និងក្រសួងពាក់ព័ន្ធ ក្នុងការងារថែទាំសុខភាពបឋម គប្បីចាត់តាំងក្រុមបង្គោលមួយសំរាប់គណៈកម្មការ ឬ លេខាធិការដ្ឋានខាងការថែទាំសុខភាពបឋម ដើម្បីធានានូវសកម្មភាព និងការផ្តត់ផ្គង់របាយការណ៍ទៀងទាត់ ។

**មាត្រា ៧ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា បណ្តាស្ថាប័ន និងអភិបាលខេត្ត-ក្រុង ដែលមានការពាក់ព័ន្ធ ព្រមទាំងឯកឧត្តម អស់លោក ដែលមានទៅក្នុងមាត្រា ២ និង មាត្រា ៣ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខានិងត្រា ហត្ថលេខានិងត្រា

**នរោត្តម រណឫទ្ធិ ហ៊ុន សែន**

* * *

*រាជធានីភ្នំពេញ , ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ១៩៩៥*

## អនុក្រឹត្យលេខ ៤១ អនក្រ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

_បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា